# សន្លឹកព័ត៌មានសាធារណៈ

Ottawa County Health Department

## រោគសួតហាន់តាវីរុស [HANTAVIRUS PULMONARY SYNDROME]

### តើរោគសួតហាន់តាវីរុសគឺជាអ្វី?

នេះជារោគសួតមួយដ៏ធ្ងន់ ហើយជារឿយៗ អាចសម្លាប់មនុស្សបាន ។ វាត្រូវបានឆ្លងពីសត្វកណ្ដុរ ហើយច្រើនតែមាននៅប្រទេសសហរដ្ឋអាមេរិក ភាគខាងលិច ។

### តើរោគហាន់តាវីរុសត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?

- មនុស្សអាចឆ្លងរោគនេះ តាមរយៈវិធីទាំងឡាយខាងក្រោមនេះ:
- ប៉ះពាល់អាចម៍កណ្ដុរ ដែលមានមេរោគនេះ
- ដកដង្ហើមចូល នូវចុណ្ណភាគវីរុសពីទឹកនោមអាចម៍ ឬទឹកមាត់របស់សត្វកណ្ដុរដែលមានមេរោគនេះ
- កណ្ដុរខាំ
- ធម្មតា វាមិនឆ្លងពីមនុស្សទៅមនុស្សទេ

### តើអាចមានរោគសញ្ញាអ្វីខ្លះ?

- ក្ដៅខ្លួន (101-104 F)
- ឈឺក្បាល
- ឈឺក្រពះ
- ឈឺសន្លាក់ឆ្អឹង
- ឈឺចង្កេះ
- ក្អួត និងអារម្មណ៍ចង់ក្អួត
- ពិបាកដកដង្ហើម

### តើរោគហាន់តាវីរុសត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្ដេច?

តាមរយៈការពិនិត្យឈាម ។

### តើរោគហាន់តាវីរុសត្រូវបានព្យាបាលយ៉ាងដូចម្ដេច?

គ្មានថ្នាំបន្សាប ឬថ្នាំបង្ការសម្រាប់រោគនេះទេ ។ បើអ្នកចាប់ផ្ដើមមានរោគសញ្ញា នោះត្រូវទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់អ្នក ហើយកុំភ្លេចប្រាប់គាត់ បើអ្នកបានប៉ះពាល់នឹងសត្វកណ្ដុរ ។

### តើរោគនេះអាចបង្ការបានយ៉ាងដូចម្ដេច?

វីរុសនេះ ដែលអាចរស់នៅក្នុងខ្យល់អាកាស ហើយនៅលើផ្ទៃផ្សេងៗ នោះអាចសម្លាប់បាន ដោយថ្នាំលាងសម្អាតផ្ទះភាគច្រើន ដូចជាអូសាវ៉ែល ឬអាកុល ។

### សម្រាប់ព័ត៌មានបន្ថែម អំពីរោគហាន់តាវីរុស:

Ottawa County Health Department
www.miOttawa.org
Center for Disease Control and Prevention
www.cdc.gov/ncidod/diseases/hanta/hps.index.htm
ទូរស័ព្ទ: (888) 246-2675

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វិបសាយ: www.miOttawa.org